Australian Government
Department of Human Services

ខ្ញុំទើបតែបានចូលទៅក្នុង Centrelink ហើយខ្ញុំចេះតែឃើញសញ្ញា "គ្រប់គ្រាន់ហើយ" នៅគ្រប់កន្លែង។ តើអ្នកដឹងថាវាចង់និយាយពីអ្វីដែរឬទេ?

ចាស ពួកគេកំពុងតែផ្សព្វផ្សាយការគាំទ្រ និង សេវាកម្មដែលមាននៅឯនាយកដ្ឋានសេវាកម្មមនុស្សជាតិសម្រាប់អ្នកដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ។

តើគេផ្តល់ការគាំទ្រ និង សេវាកម្មអ្វីខ្លះ?

វាយោងតាមកាលៈទេសៈ ពួកគេអាចបញ្ជូនអ្នកឲ្យទៅទទួលសេវាកម្មគាំទ្រពីអ្នកជំនាញនៅក្នុងសហគមន៍របស់អ្នក។ អ្នកក៏អាចនឹងត្រូវគេបញ្ជូនឲ្យទៅជួបជាមួយបុគ្គលិកសង្គមកិច្ចដែលអាចផ្តល់ការប្រឹក្សានិងការគាំទ្រ និង ជួយឲ្យអ្នកអាចទទួលបាននូវប្រាក់ឧបត្ថម្ភមួយចំនួនផងដែរ។

ចាស វាជាការល្អណាស់ដែលដឹងថាមានជំនួយបែបនេះ។ ខ្ញុំមានមិត្តម្នាក់ដែលមើលទៅហាក់ដូចជាកំពុងតែមានទំនាក់ទំនងមិនល្អជាមួយនឹងស្វាមីនាង។ គាត់មិនបានជារំលោភបំពានលើរូបរាងកាយនាងនោះទេ ប៉ុន្តែនាងគ្មានសិទ្ធិជួបជាមួយមិត្តភក្តិឬក៏ក្រុមគ្រួសាររបស់នាងឡើយបើគ្មានការអនុញ្ញាតពីស្វាមីនាងនោះ ហើយនាងមិនមានប្រាក់កាសសម្រាប់ទិញម្ហូបអាហារឬក៏សម្លៀកបំពាក់នោះទេ។ នាងពិតជាមិនសប្បាយចិត្តទេ ហើយក៏មិនដឹងថាត្រូវធ្វើយ៉ាងណាដែរ។

អំពើហិង្សាក្នុងគ្រួសារគឺមិនមែនត្រឹមតែជាអំពើហិង្សាលើរូបរាងកាយប៉ុណ្ណោះនោះទេ។ វាអាចរួមបញ្ចូលទាំងអាកប្បកិរិយាដែលជាការគំរាមកំហែង គ្រប់គ្រងហួងហែង ឬក៏មានបំណងបំភិតបំភ័យឲ្យខ្លាចជាដើម។

ខ្ញុំមិនបានដឹងពីរឿងនេះសោះ។ នាងក៏ទើបតែកំពុងរៀននិយាយភាសាអង់គ្លេស ខណៈដែលនាងបានរើមកនៅទីនេះប្រហែលជាមួយឆ្នាំមុន។ តើនាងអាចនិយាយទៅកាន់នាយកដ្ឋានសេវាកម្មមនុស្សជាតិបានដែរឬទេ?

ចាស ពិតជាបាន។ នាងអាចទូរសព្ទទៅកាន់ Department of Human Services តាមរយៈលេខ ១៣១២០២
ដើម្បីនិយាយជាមួយនរណាម្នាក់ជាភាសារបស់នាង។
ជម្រើសមួយទៀត នាងក៏អាចទូរសព្ទទៅ 1800RESPECT តាមរយៈលេខ ១៨០០ ៧៣៧ ៧៣២ ហើយនិយាយជាមួយនរណាម្នាក់ជាភាសារបស់នាងផងដែរ។ ពួកគេផ្តល់នូវសេវាទូរសព្ទដោយឥតគិតថ្លៃ និងការប្រឹក្សាតាមប្រព័ន្ធអនឡាញដល់អ្នកដែលធ្លាប់ជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ហើយក៏អាចបញ្ជូននាងឲ្យទៅរកជំនួយពីសេវាកម្មក្នុងតំបន់ទៀតផង។

ខ្ញុំមិនប្រាកដថា នាងមានបំណងចង់និយាយជាមួយនរណាម្នាក់នៅឡើយនោះទេ តើខ្ញុំអាចប្រាប់ឲ្យនាងស្វែងរកព័ត៌មានបន្ថែមបាននៅកន្លែងណាដែរ?
`

នាងអាចបើកមើលគេហទំព័រៈ humanservices.gov.au/yourlanguage ឬក៏ 1800respect.org.au/languages។ ពួកគេមានព័ត៌មានស្តីពីអំពើហិង្សាក្នុងគ្រួសារជាច្រើនភាសា។

អរគុណ។ ខ្ញុំនឹងចែករំលែកព័ត៌មាននេះជាមួយនាង។